ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

THE GARMENT MANUFACTURERS ASSOCIATION IN CAMBODIA (GMAC)
THE SECRETARIAT
IN No : 104
Date: 10.03.11 Time: 9:15
For : GMAC

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា
ការិយាល័យគយ និងរដ្ឋាករ
អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
លេខ: ៣៩៤ គរ.អអកព

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០១១

**ប្រធានការិយាល័យគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ**

**ជម្រាបមក**

**លោក លោកស្រី ជាប្រធានក្រុមហ៊ុននាំចេញ-នាំចូល**

**តាមមាត់ច្រកការិយាល័យគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ**

**កម្មវត្ថុ ៖** ការរំឭកឡើងវិញ ស្តីពីការបំពេញបែបបទគយនៅ ការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ។

**យោង ៖** លិខិតលេខ ១៤៩៥ គរ.អអកព ចុះថ្ងៃទី០៧ ខែតុលាឆ្នាំ២០០៩ របស់ ការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ ស្តីពីការបំពេញបែបបទគយនៅ ការិយាល័យគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ ប្រធានការិយាល័យគយ និងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ មានកិត្តិយសសូមជម្រាបមក លោក លោកស្រីជាប្រធានក្រុមហ៊ុននាំចេញ-នាំចូលទាំងអស់បានជ្រាបថា ៖តាមការសង្កេតរបស់ការិយាល័យ មានក្រុមហ៊ុននាំចេញនាំចូលនិងដើងសាគយមួយចំនួននៅតែមិនគោរពតាមការណែនាំរបស់ការិយាល័យ ដោយនៅតែបង្កការខុសឆ្គងដដែលជាដដែលម្តងហើយម្តងទៀតក្នុងការបំពេញបែបបទគយនាំចេញនិងនាំចូល ។

ដើម្បីកែលម្អភាពអសកម្មទាំងនេះ ចៀសវាងការរាំងស្ទះដោយប្រការផ្សេងៗ ការិយាល័យគយ សូមធ្វើការក្រើនរំឭកដល់លោក លោកស្រីទាំងអស់នូវចំណុចមួយចំនួនដូចខាងក្រោម៖

១. ត្រូវមានឯកសារច្បាប់ដើម(Original)គ្រប់គ្រាន់ភ្ជាប់ជាមួយប្រតិវេទន៍គយរួមមាន ៖

- វិក្កយបត្រនិងបញ្ជីវេចខ្ចប់ (Invoice & Packing List)
- អញ្ញាតប័ណ្ណដឹកជញ្ជូនផ្លូវអាកាស (Master Air waybill and/or House Air waybill)
- លិខិតអនុញ្ញាតគយ (Customs Permit )ចំពោះទំនិញហាមឃាត់ឬជាប់កម្រិតកំណត់(យោងអនុក្រឹត្យលេខ២០៩ អនក្រ.បក្រ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការដាក់ឲ្យប្រើប្រាស់ទំនិញហាមឃាត់និងទំនិញជាប់កម្រិតកំណត់)។
- និងឯកសារពាក់ព័ន្ធផ្សេងៗទៀតក្នុងករណីចាំបាច់

២. ចំពោះទំនិញនាំចេញ ត្រូវដឹកទំនិញមកដល់ទីលានផ្ទុកទំនិញដែលមានរយៈពេលយ៉ាងតិចបំផុតពីរម៉ោងតាមការជូនដំណឹងរបស់ក្រុមហ៊ុនSCA/CAMS (សូមមើលបន្ថែមក្នុងwebsite:www.cambodis-airports.com) ទើបអនុញ្ញាតឲ្យបំពេញបែបបទគយក្នុងប្រព័ន្ធអាស៊ីគូដា។

៣. ក្នុងករណី មានទំនិញនាំចេញ-នាំចូល ក្រៅម៉ោងរដ្ឋបាល ក្រុមហ៊ុននាំចេញ-នាំចូល ត្រូវជូនដំណឹងមកការិយាល័យគយជាមុន ដើម្បីឲ្យការិយាល័យគយ មានលទ្ធភាពចាត់ចែងកម្លាំងមន្ត្រីគយបានទាន់ពេលវេលាតាមនីតិវិធីគយ។

៤. រោងចក្រកាត់ដេរទាំងអស់ត្រូវឲ្យប្រាកដថា ខោអាវបានដេរនិងវេចខ្ចប់រួចហើយ និងមានទំនិញគ្រប់ចំនួនទើបធ្វើការនាំចេញ។ មិនមែនដេរមិនទាន់ហើយឬកំពុងតែត្រួតពិនិត្យគុណភាពទំនិញដោយQC ហើយប្រញាប់ប្រញាល់ឲ្យបុគ្គលិកខ្លួនមកបំពេញបែបបទគយដើម្បីឲ្យទាន់ជើងយន្តហោះ ហើយក្រោយមកសុំគយលុបលេខវិញដោយសារទំនិញដេរមិនទាន់ឬទំនិញធ្លាក់QCនោះទេ។ ជាក់ស្តែង ដូចជាក្រុមហ៊ុនSGL

CAMBODIA បានសុំចេញពេលយប់នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១១ ហើយមិនបានចេញវិញដោយប្រាប់ថាក្រុមហ៊ុនគ្មានទំនិញចេញគ្រប់ចំនួន គ្មានឯកសារគ្រប់គ្រាន់។

៥.ត្រូវមានបុគ្គលិកចេះបំពេញបែបបទគយស្ទាត់ជំនាញនិងយល់ដឹងពីច្បាប់និងនីតិវិធីគយ ក្នុងការបំពេញបែបបទឯកសាររដ្ឋបាលតែមួយ(SAD-Single Administration Document)ឲ្យបានត្រឹមត្រូវ។

៦.ត្រូវមានបុគ្គលិកគ្រប់គ្រាន់ក្នុងការបំពេញបែបបទគយនាំចេញនាំចូល ហើយត្រូវតែជាបុគ្គលិករបស់ក្រុមហ៊ុនយ៉ាងពិតប្រាកដដោយភ្ជាប់ជាមួយនូវប័ណ្ណសម្គាល់ខ្លួនដែលបញ្ជាក់ថាជាបុគ្គលិកក្រុមហ៊ុនឬបើជាជើងសាគយ ត្រូវមានភ្ជាប់លិខិតបញ្ជាក់ជើងសាគយពាក់ភ្ជាប់នៅនឹងខ្លួន។

៧.ពេលមានឯកសារគ្រប់គ្រាន់ត្រូវណែនាំបុគ្គលិកខ្លួនមកបំពេញបែបបទគយចាប់ពីម៉ោង៧និង៣០នាទីព្រឹក។

៨. ត្រូវតាមដានការងារបុគ្គលិករបស់ខ្លួន ដើម្បីកុំឲ្យបុគ្គលិកធ្វើយថាមកបំពេញបែបបទគយ ប៉ុន្តែបែរជាទៅធ្វើកិច្ចការផ្សេងៗសិន រួចទម្លាក់កំហុសថាមកបំពេញបែបបទគយយឺត។

៩. ត្រូវមានបុគ្គលិកគ្រប់គ្រាន់ឲ្យសមាមាត្រនឹងការងារ ចៀសវាងយឺតយ៉ាវ។

១០. ក្នុងករណីយឺតយ៉ាវដែលបង្កឡើងដោយមន្ត្រីមានសមត្ថកិច្ចខិលខូចមួយចំនួនតូច សូមមេត្តាផ្តល់ព័ត៌មានមកការិយាល័យគយ តាមរយៈប្រអប់សំបុត្រដែលបានដាក់ជូន ដើម្បីឲ្យការិយាល័យគយមានមូលដ្ឋានចាត់វិធានការណ៍បានទាន់ពេលវេលាតាមសំណូមពរ។

១១. សូមគ្រប់រោងចក្រនិងក្រុមហ៊ុនទាំងអស់ មេត្តារួសរាន់ប្រគល់ឯកសារដល់ជើងសាគយដែលត្រូវបានប្រគល់សិទ្ធិឲ្យបំពេញបែបបទគយ ចៀសវាងពន្យាពេលដល់ម៉ោង៩ឬ១០ ហើយម្ចាស់រោងចក្រទារយកទំនិញភ្លាមៗ ដែលជើងសាគយមិនអាចធ្វើជូនបានទាន់ពេល។

១២. ក្រុមហ៊ុននាំចេញនាំចូលណាដែលជាប់លក្ខណៈវិនិច្ឆ័យ News Importer និង Unknown Traders List ហើយការិយាល័បានអនុញ្ញាតឲ្យទំនិញចេញមុន រួចត្រូវរូតរះទៅបំពេញបែបបទធ្វើនិយ័តកម្មជាក្រោយនៅការិយាល័យគ្រប់គ្រងហានិភ័យនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជាឲ្យបានទាន់ពេលវេលា។

ការអនុវត្តពុំបានតាមខ្លឹមសារសេចក្តីជូនដំណឹងនេះ ការិយាល័យគយពុំទទួលខុសត្រូវចំពោះការយឺតយ៉ាវដោយថាហេតុនាំឲ្យរាំងស្ទះដល់កិច្ចដំណើរការបំពេញបែបបទគយ របស់លោក លោកស្រីឡើយ ចំពោះជើងសាគយណាដែលធ្លាប់បានចុះកិច្ចសន្យាជាមួយការិយាល័យគយនិងរដ្ឋាករអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនាពេលកន្លងមក អាចទទួលរងការផាកពិន័យឬធ្វើលិខិតព្រមាន។

ការិយាល័យគយ សង្ឃឹមថា លោក លោកស្រី ជាប្រធានក្រុមហ៊ុននាំចេញនាំចូលទាំងអស់ចូលរួមសហការនឹងគោរពតាមការណែនាំនេះ។

សូម លោក លោកស្រី ទទួលនូវការរាប់អានដ៏ស្មោះ ពីខ្ញុំ

**ប្រធានការិយាល័យគយនិងរដ្ឋាករ**
**អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ**

**ខៀវ_សំអាន**

ចម្លងជូន ៖
- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយនិងរដ្ឋាករកម្ពុជា
- លោកអគ្គនាយករងទទួលបន្ទុកការិយាល័យគយនិងរដ្ឋាករ
អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ
"ដើម្បី ៖សូមមេត្តាជ្រាបជាខ្ពង់ខ្ពស់"
- លោក លោកស្រីជាប្រធានក្រុមហ៊ុននាំចេញនាំចូល
- លោកប្រធានសមាគមរោងចក្រកាត់ដេរនៅកម្ពុជា
"ដើម្បី ៖សូមមេត្តាជ្រាបនិងផ្សព្វផ្សាយអនុវត្ត"
- ឯកសារ